ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៥០/២១ ក.ប/ស.ស.រ.ប.ស.ស

# សេចក្តីសម្រេច

# ស្តីពី

# ការកែសម្រួលសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ របស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញសេចក្តីសម្រេចលេខ០០២/១៥ ក.ប/ស.ស.រ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិសន្តិសុខសង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ុក វណ្ណថាត** | ទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - ឯកឧត្តម **ម៉េង ហុង** | អគ្គនាយករង នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - ឯកឧត្តម **ហេង សុផាន់ណារិទ្ធ** | អគ្គនាយករង នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោក **ភាំង ម៉ូនីកា** | អគ្គលេខាធិការរង នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | សមាជិក |
| - លោកវេជ្ជបណ្ឌិត **ទត ម៉ូឡារី** | ប្រធាននាយកដ្ឋាន នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោក **អ៊ុក សំអូន** | ប្រធាននាយកដ្ឋាន នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោកវេជ្ជបណ្ឌិត **ហាន់ នព្វគុណ** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានពេទ្យការងារ | សមាជិក |
| - លោក **ផេង សុភាត** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |

**ប្រការ២ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- សាមីអង្គភាព "ដើម្បីជ្រាប"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គម**

លេខ : ៩៤៤/២១ ប.ស.ស.

ខុទ្ទកាល័យរដ្ឋមន្ត្រី
ចូល លេខ 5076
ថ្ងៃទី 23 ខែ 11 ឆ្នាំ 21
ម៉ោង 11:00

## កំណត់បង្ហាញ

## សូមគោរពជូន

## ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**កម្មវត្ថុ** ៖ សំណើសុំហត្ថលេខាលើសេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិសន្តិសុខសង្គម។

**យោង** ៖ សេចក្តីសម្រេចលេខ ០០២/១៥ ក.ប/ស.ស.រ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម។

<table>
<tr><th>យោបល់សម្រេចឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី</th><td rowspan="2">សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន មានសមាសភាពមួយចំនួនត្រូវបានផ្លាស់ប្តូរ និងសមាសភាពមួយចំនួនបានប្តូរតួនាទីនៅក្នុងស្ថាប័នរបស់ខ្លួន ដូច្នេះ ប.ស.ស. ស្នើសុំរៀបចំកែសម្រួលសមាសភាពក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន ដូចមានសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិរបបសន្តិសុខសង្គម គោរពជូនភ្ជាប់ជាមួយ។<br><br>អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី មេត្តាពិនិត្យសម្រេចដោយសេចក្តីអនុគ្រោះ។<br><br>សូម ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។<br><br>ថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥<br>រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១<br>ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា<br>អគ្គនាយកបេឡាជាតិសន្តិសុខសង្គម<br><br>អ៊ុក_សមវិទ្យា</td></tr>
<tr><td>28/11</td></tr>
</table>